# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រសិទ្ធិពរលើប្រេងនៅភ្នំពេញថ្មី
# ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨
## *តើព្រះជាម្ចាស់ជានរណា?*

អត្ថបទទី១៖ អស ៦១,១-៣.៦.៨
អត្ថបទទី២៖ វវ ១,៥-៨
ដំណឹងល្អ៖ លក ៤,១៦-២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះនៅពេលយើងស្តាប់អត្ថបទទីមួយ អត្ថបទទីពីរ និងគម្ពីរដំណឹងល្អ យើងបាន ស្តាប់ **យើងជាព្យាការី**ដើម្បីប្រកាសដំណឹងល្អដល់ជនក្រីក្រ **យើងជាបូជាចារ្យ**ដើម្បីថ្វាយខ្លួនរបស់យើងទៅដល់ព្រះជាម្ចាស់ និងដើម្បីថ្វាយបងប្អូនទាំងអស់ឲ្យបងប្អូនទាំងអស់ទៅជាអង្គតែមួយជាមួយព្រះជាម្ចាស់ និង**យើងជាព្រះមហាក្សត្រ**ដើម្បីបម្រើបងប្អូនដែលកំពុងស្រេកឃ្លាន ដែលកំពុងមានសេចក្តីត្រូវការ ដែលកំពុងខ្វះសេចក្តីសង្ឃឹម។ នេះជាមហាកិត្តិយស នេះជាឋានៈរបស់យើងជាគ្រីស្តបរិស័ទទាំងអស់ នៅថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹកយើងជាព្យាការីផង យើងជាបូជាចារ្យផង យើងជាព្រះមហាក្សត្រផង ដើម្បីបំពេញតួនាទីរបស់យើងជាសាវ័ករបស់ព្រះគ្រីស្ត ដែលត្រូវការបង្ហាញផ្លែនៅក្នុងជីវិត។ ផ្លែដែលយើងត្រូវការបង្ហាញយ៉ាងជាក់ស្តែង នៅពេលយើងចាប់ផ្តើមប្រកាសដំណឹងល្អតាមរយៈជីវិតរបស់យើង ច្រើនជាងតាមរយៈធម្មទេសនា ឬតាមរយៈបបូរមាត់របស់យើង។

ម្សិលមិញ សម្តេចប៉ាប បានចេញសៀវភៅមួយសម្រាប់យុវជននៅក្នុងពិភពលោក ដោយមានឃ្លាមួយនិយាយថា "**យុវជនអើយ! ប្រសិនបើយើងចង់ផ្តល់សក្ខីភាព កុំធ្វើតាមបបូរមាត់ តាមសេចក្តីប្រកាស ប៉ុន្តែធ្វើតាមរបៀបដែលរស់នៅជាប្រចាំថ្ងៃ**"។

បងប្អូនជាទីស្រឡាញ់!

នៅក្នុងព្រះយេស៊ូគ្រីស្ត យើងបានទទួលបេសកកម្មមួយដ៏អស្ចារ្យ នៅថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីរស់នៅជាព្យាការី ជាបូជាចារ្យ ជាព្រះមហាក្សត្រ នៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គមបច្ចុប្បន្ននេះ។ សង្គមបច្ចុប្បន្ននេះ មិនមែនជាសង្គមដែលយើងស្គាល់នៅស.វទី២០ ប៉ុន្តែនៅស.វទី២១ ប្រទេសកម្ពុជាយើង ជាសង្គមមួយដែលបានអភិវឌ្ឍន៍យ៉ាងលឿនណាស់។ នៅកំពង់សោម ពីមួយថ្ងៃទៅមួយថ្ងៃយើងឃើញមានអាគារខ្ពស់ទៅៗ យើងឃើញផ្លូវថ្មីៗ យើងឃើញមានកាស៊ីណូយ៉ាងច្រើន នៅភ្នំពេញយើង

នឹងមានរថភ្លើងទៅព្រលានយន្តហោះ នៅមុនចូលឆ្នាំខ្មែរខាងមុខ យើងមានសណ្ឋាគារធំៗ យើងមានផ្សារទំនើបជាច្រើន។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រទេសយើងកំពុងអភិវឌ្ឍន៍ ប៉ុន្តែ ណែនាំវិស័យសាសនាកាន់តែខ្សោយទៅៗ។ នៅស.វទី២១ ដោយនឹកឃើញលិខិតរបស់ស ម្តេចប៉ាបសម្រាប់រដូវ៤០ថ្ងៃ នៅស.វទី២១ បានកំពុងកសាងសង្គមថ្មីដែលយកមូលដ្ឋានគ្រឹះ ទីមួយ លុយប្រាក់ ទ្រព្យសម្បត្តិ ទីពីរ អំណាច ដោយគិតថានេះជាគុណធម៌ដែលណែនាំឲ្យ យើងរកឃើញសេចក្តីសុខសាន្ត។ នៅពេលយើងមានឋានន្តរស័កខ្ពស់ យើងមានសញ្ញាប ត្រខ្ពស់យើងបានទទួលការសរសើរតាមរបៀបមនុស្សលោក តែមិនមែនតាមរបៀបព្រះជា ម្ចាស់ទេ។ នៅក្នុងសង្គមបច្ចុប្បន្ននេះណែនាំឲ្យព្រះជាម្ចាស់ ដែលមានព្រះសូរសៀងស្រា លៗពិបាកស្តាប់លឺ នៅក្នុងសម្លេងនៃបណ្តាញផ្សព្វផ្សាយសង្គម នៅក្នុងសម្លេងនៃសេចក្តី ពិត និងមិនមែនសេចក្តីពិត។ ព្រះជាម្ចាស់ដែលជាសេចក្តីពិត ព្រះជាម្ចាស់ដែលជាជីវិត ព្រះជាម្ចាស់ដែលជាផ្លូវ ពិបាករកឃើញផ្លូវមួយ ពិបាករកឃើញទីតាំងមួយ ដើម្បីចេញស ម្លេងឲ្យមនុស្សយើងស្តាប់លឺ។

យប់នេះព្រះជាម្ចាស់កំពុងគោះទ្វារ នៃបេះដូងរបស់យើង នៃដួងចិត្តរបស់យើង និង ព្រះជាម្ចាស់កំពុងមានព្រះបន្ទូលដល់យើងរៀងៗខ្លួនថា "**ខ្ញុំបានជ្រើសរើសកូនដើម្បីទៅជា ព្យាការីនិងប្រកាសដំណឹងល្អដល់អ្នកក្រីក្រ ខ្ញុំបានជ្រើសរើសកូនដើម្បីធ្វើជាបូជាចារ្យនិង អធិដ្ឋានឲ្យពិភពលោករបស់យើងទៅជាពិភពដ៏វិសុទ្ធ ខ្ញុំបានជ្រើសរើសកូនដើម្បីធ្វើជាព្រះ មហាក្សត្រនិងបម្រើដល់មនុស្សដែលមានឋានៈធំ និងមនុស្សដែលមានឋានៈតូចតាចដែល សង្គមលែងមើលឃើញ**។ ប្រទេសកម្ពុជាបានចូលនៅក្នុងស.វទី២១ ពិតមែនយើងជាប្រជា រាស្ត្រដ៏តូចមួយគឺប្រជារាស្ត្ររបស់ព្រះយេស៊ូគ្រីស្ត ប៉ុន្តែយើងជាមនុស្សដែលត្រូវការពោរ ពេញដោយកំលាំង ពោរពេញដោយសេចក្តីក្លាហាន ដើម្បីប្រកាសដំណឹងល្អ និងថ្ងៃនេះ ដំណឹងល្អទៅជារូបរាងដ៏ពិតប្រាកដមែន។

លោកឪពុកជាទីស្រឡាញ់!

ថ្ងៃនេះយើងជាបូជាចារ្យ ដែលបានទទួលឋានៈមួយនៅក្នុងរបៀបយ៉ាងពិសេស ដោយសារយើងបានទទួលប្រេងអភិសេក។ នៅថ្ងៃ ដែលយើងបានទទួលអគ្គសញ្ញាតែង តាំងជាបូជាចារ្យ យើងបានទទួលប្រេងអភិសេក តាមរយៈលោកអភិបាលដែលត្រៀបដៃ

ដាក់ដៃលើក្បាលរបស់យើង លាតដៃដើម្បីឲ្យយើងទៅជាបូជាចារ្យ ព្យាការី ព្រះមហាក្សត្រ ដែលព្រះជាម្ចាស់បានជ្រើសរើស ដែលព្រះជាម្ចាស់បានតែងតាំង និងព្រះជាម្ចាស់កំពុងចាត់ឲ្យទៅប្រកាសដំណឹងល្អ ឲ្យទៅអធិដ្ឋាន និងឲ្យទៅបម្រើអស់ពីកម្លាំងកាយកម្លាំងចិត្ត។ បន្តិចទៀតយើងជាបូជាចារ្យទាំងអស់ នឹងប្រកាសពាក្យសច្ចាររបស់យើងសារជាថ្មីអស់ពីដួងចិត្តរបស់យើង នៅពេលនោះយើងនឹកឃើញពេលយើងបានឆ្លើយ **បាទខ្ញុំសុខចិត្តដើរតាមព្រះយេស៊ូ**នៅមុនគេបង្អស់នៅក្នុងជីវិតរបស់យើង។ ប្រហែលនៅពេលនោះ យើងដូចលោកសិលា ពោរពេញដោយកម្លាំង ពេលព្រះយេស៊ូប្រាប់ទៅលោកសិលា **ឥលូវនេះនេសាទមនុស្សវិញ** ពេលនោះលោកសិលាគាត់ទៅដោយកម្លាំង ដោយអំណរសប្បាយ។ លោកសិលា បានប្រកាសមុនគេបង្អស់ថា **ព្រះអង្គជាព្រះគ្រីស្តពិតមែន ជាព្រះបុត្រារបស់ព្រះជាម្ចាស់**។ នៅក្នុងជីវិតរបស់យើង ដូចលោកសិលាដែរ ការឯកភាពរបស់យើង ការផ្ញើជីវិតទៅលើព្រះជាម្ចាស់របស់យើងធ្លាក់បន្តិច ដូចលោកសិលាយើងធ្លាក់ទឹក ទោះបីយើងខិតខំដើរលើទឹក ទោះបីយើងរត់តាមព្រះយេស៊ូ ប៉ុន្តែយើងលិចទឹកអស់ហើយតែនៅពេលនោះយើងដឹងថា យើងមានព្រះយេស៊ូដើម្បីចាប់ដៃយើង បន្តធ្វើដំណើរជាមួយយើង បន្តត្រាស់ហៅយើង។ យើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ **កូនអើយ! កុំខ្លាចអី ខ្ញុំនៅទីនេះ**។ យើងសម្លឹងមើលព្រះយេស៊ូ ដែលកំពុងសម្លឹងមើលយើងដែរ ដើម្បីលើកលែងទោសឲ្យយើង ព្រះយេស៊ូថា **លោកស្រឡាញ់ខ្ញុំឬទេ?** ប្រហែលនៅពេលនោះ ព្រះយេស៊ូកំពុងយំកំពុងពិបាក ប៉ុន្តែព្រះយេស៊ូកំពុងលើកលែងទោសឲ្យយើង និងណែនាំឲ្យយើងឲ្យពោរពេញដោយសេចក្តីស្រឡាញ់តទៅទៀត។

យប់នេះឲ្យយើងនឹករលឹក ដល់ពេលវេលាដែលលោកអភិបាលបានដាក់ដៃលើក្បាលរបស់យើង ដើម្បីឲ្យយើងទៅជាបូជាចារ្យ ឲ្យយើងនឹករលឹកនៅពេលបូជាចារ្យទាំងអស់ដែលបានដាក់ដៃលើក្បាលរបស់យើង ដើម្បីស្វាគមន៍យើងនៅក្នុងក្រុមបូជាចារ្យ ដែលជាក្រុមមិត្តសម្លាញ់របស់ព្រះគ្រីស្តយេស៊ូ។ យប់នេះឲ្យយើងនឹករលឹកដល់ព្រះហស្តរបស់ព្រះយេស៊ូ ដែលបានចាប់ដៃពីថ្ងៃដំបូងបង្អស់ដើម្បីធ្វើដំណើរជាមួយយើង និងបន្តចាប់ដៃរបស់យើង ដើម្បីឲ្យយើងទៅមុខនៅក្នុងជីវិតរបស់យើង ទោះបីជួនកាលយើងលិចទឹកដល់ក ប៉ុន្តែព្រះយេស៊ូនៅដើម្បីចាប់ដៃយើង ឲ្យយើងធ្វើដំណើរបន្តទៅទៀត។ យប់នេះខ្ញុំសូមឲ្យលោកឪពុកមើលដៃផ្ទាល់ខ្លួន ជាដៃហ្នឹងដែលយើងត្រៀបទៅលើនំ និងលើស្រា ដើម្បីឲ្យ

នំនេះ ស្រានេះ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ទៅជាព្រះកាយ និងព្រះលោហិត របស់ព្រះគ្រីស្ត។ ជាដៃនេះ ដែលជួយឲ្យបងប្អូនទទួលព្រះពរពីព្រះជាម្ចាស់ ជាដៃនេះដែលទទួលស្វាគមន៍ ដែលលើកលែងទោសឲ្យ ដោយណែនាំឲ្យបងប្អូនមានសេចក្ដីសង្ឃឹម។ ជាដៃនេះដែលបានថ្នាក់ថ្នមកូនក្មេងដែលឪពុកម្ដាយបោះបង់ចោល ជាដៃនេះដែលឱបបងប្អូនដែលកំពុងអស់សង្ឃឹមនៅក្នុងជីវិតរបស់គេ។ ជាដៃនេះដែលជូតមុខជូតទឹកភ្នែក ឲ្យបងប្អូនដែលកំពុងយំ ជាដៃនេះដែលទះដៃដើម្បីអបអរសាទរ ដើម្បីលើកទឹកចិត្តបងប្អូន ជាដៃនេះដែលយើងបានលើកប្រណមដើម្បីអធិដ្ឋាន និងដើម្បីជិតស្និទ្ធថែមទៀតជាមួយព្រះយេស៊ូ ដែលបានជ្រើសរើសយើង និងជាដៃនេះដែលណែនាំឲ្យបងប្អូនយើង អាចទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត។

យប់នេះខ្ញុំអញ្ជើញលោកឪពុកទាំងអស់ ឲ្យសម្លឹងមើលព្រះហស្តរបស់ព្រះយេស៊ូផ្ទាល់ ដោយសារជាព្រះហស្តរបស់ព្រះយេស៊ូដែលប្រទានជីវិតឲ្យយើង ជាព្រះហស្តរបស់ព្រះយេស៊ូដែលចាប់ដៃយើង ដើម្បីឲ្យយើងធ្វើដំណើរជាមួយបងប្អូនទាំងអស់ ដែលព្រះយេស៊ូបានប្រទានឲ្យយើង។ នៅក្នុងឆ្នាំនៃគ្រួសារ ឲ្យយើងស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ ការត្រាស់ហៅរបស់ព្រះសហគមន៍ សម្រាប់យើងជាបូជាចារ្យឲ្យយើងធ្វើទាំងឪពុកធ្វើទាំងម្ដាយ។ ថ្ងៃនេះយើងបានឃើញរូបយ៉ាងច្បាស់ លោកតាដែលចាប់កូនពៅ មានទាំងដៃមនុស្សស្រី មានទាំងដៃមនុស្សប្រុស ដោយសារនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់មានទាំងព្រះហឫទ័យម្ដាយ មានទាំងព្រះហឫទ័យឪពុក។ សម្រាប់យើងជាបូជាចារ្យ ឲ្យយើងមានទឹកចិត្តដូចម្ដាយផងដូចឪពុកផង ដើម្បីបម្រើបងប្អូនយើង ដើម្បីណែនាំឲ្យបងប្អូនយើងទៅជាបងប្អូនដ៏វិសុទ្ធ ដើម្បីស្រឡាញ់ដូចព្រះជាម្ចាស់ ដើម្បីលើកលែងទោសដូចព្រះជាម្ចាស់ ដើម្បីបម្រើដូចព្រះជាម្ចាស់។

នៅពេលខ្ញុំ ថ្វាយអភិបូជានៅព្រះសហគមន៍ពោធិ៍ចិនតុង ប៉ុន្មានថ្ងៃមុន គេបានច្រៀងចម្រៀងចូល **តើព្រះជាម្ចាស់ជានរណា?** ក្រោយមកខ្ញុំបានងើបមុខ ខ្ញុំបានឃើញនៅខាងលើមានឈើឆ្កាងដែលបង្ហាញសិរីរុងរឿងរបស់ព្រះគ្រីស្ត នៅខាងក្រោយមានព្រះយេស៊ូកំពុងជប់លៀងជាមួយក្រុមគ្រីស្តទូត និងនៅកណ្ដាលបានសរសេរថា **ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់**។ ព្រះជាម្ចាស់ជានរណា? ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ យើងជាបូជាចារ្យ យើងជាព្រះមហាក្សត្រ យើងជាព្យាការី ដើម្បីឲ្យសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់

ទៅដល់បងប្អូនឯទៀតៗដោយដៃរបស់យើង នៅក្នុងដៃរបស់យើង យើងប្រមូលសេចក្តីស្រឡាញ់ ដើម្បីឲ្យបងប្អូនរបស់យើងទទួលជីវិតដ៏បរិបូរណ៍ គឺជីវិតមកពីព្រះជាម្ចាស់។ ហេតុនេះហើយ ឲ្យយើងទុកព្រះហស្តរបស់ព្រះជាម្ចាស់ក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យយើងធ្វើជាព្យាការី ធ្វើជាបូជាចារ្យ និងធ្វើជាព្រះមហាក្សត្រ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ពិតមែន។ សូមព្រះជាម្ចាស់ប្រទានពរដល់យើងទាំងអស់គ្នា សូមព្រះហស្តរបស់ព្រះអង្គការពារថែរក្សាយើង នៅក្នុងសេចក្តីសុខសាន្តរបស់ព្រះអង្គ នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕